ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ...៤២៥...ស.ណ./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី.០៣ ខែ.មិថុនា ឆ្នាំ២០១៥

**ជម្រាបជូន**

**លោកស្រី ចាន់ ឆារី នាយិកាប្រតិបត្តិ នៃអង្គការ RACHA**

**កម្មវត្ថុ៖** អំពីសំណើសុំគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមរបស់អង្គការ RACHA នៅក្នុងស្រុកគោលដៅចំនួន៨ ឃុំចំនួន២៤ នៃខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។

**យោង៖** -លិខិតលេខ2012-03/15LGCB ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ស្នើសុំគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម របស់អង្គការ RACHA ។
-ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកស្រីនាយិកាប្រតិបត្តិជ្រាបថា៖ លេខាធិការដ្ឋាន គ.ជ.អ.ប សូមគាំទ្រ និងសហការជាមួយអង្គការ RACHA លើការអនុវត្តផែនការសកម្មភាពផ្នែកតម្រូវការ ក្នុងផែនការយុទ្ធសាស្ត្រស្តីពី ការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលផ្តោតសំខាន់លើសេវាមូលដ្ឋានទាំងបីរួមមាន៖ ការផ្តល់សេវារបស់រដ្ឋបាលឃុំ សេវាមណ្ឌលសុខភាព និងសាលាបឋមសិក្សា នៅក្នុងឃុំចំនួន៨ ស្រុកគោលដៅចំនួន២៤ នៃខេត្តចំនួន២ គឺខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៥នេះ ដូចមានលម្អិតក្នុងតារាង ភ្ជាប់ជូនមកជាមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោកស្រីនាយិកាប្រតិបត្តិ មេត្តាចាត់ចែងអនុវត្តតាមនីតិវិធី ប្រើប្រាស់ឧបករណ៍គណនេយ្យភាពសង្គម ដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានដាក់ឲ្យអនុវត្ត និងត្រូវសហការជាមួយរដ្ឋបាលខេត្ត ស្រុក ឃុំ និងអ្នកពាក់ព័ន្ធ នៅតាមតំបន់គោលដៅដែលបានកំណត់ ឲ្យទទួលបានលទ្ធផលល្អប្រសើរ។

សូមលោកស្រីនាយិកាប្រតិបត្តិ ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ង៉ាន់ ចំរើន**

**ចម្លងជូន៖**
- រដ្ឋបាលខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ
- រដ្ឋបាលស្រុក ឃុំ គោលដៅ "ដើម្បីសហការអនុវត្ត"
- ឯកសារកាលប្បវត្តិ